# សម័យប្រជុំបព្វជិតភាព

ថ្ងៃទី 5 ខែ មេសា ឆ្នាំ 2008

## ស្ដាប់តាមគ្រប់ទាំងពាក្យរបស់ព្យាការី


អែលឌើរ ឃ្វីនទីន អិល ឃុក

នៃពួកសាវក 12 នាក់


*នៅក្នុងនាមជាអ្នកកាន់បព្វជិតភាពរបស់សាសនាចក្រ វាគឺជាការទទួលខុសត្រូវដ៏ឧឡារិករបស់យើងដើម្បីធ្វើតាមព្យាការីរបស់យើង ។*

បងប្អូនប្រុសនៃបព្វជិតភាពជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំមានអំណរគុណដោយមានវត្តមាននៅក្នុងសម័យប្រជុំនៃសន្និសីទទូទៅនេះជាមួយនឹងអ្នកទាំងអស់គ្នានៅថ្ងៃជាប្រវត្តិសាស្ត្រនេះ ។

យើងកោតសរសើរអ្នកទាំងឡាយណាដែលយកជីវិតរបស់ខ្លួនមកប្រថុយប្រថាន ដើម្បីសង្គ្រោះអ្នកដែលស្ថិតនៅក្នុងគ្រោះថ្នាក់ ។1 ពេលដែលខ្ញុំបានទៅទស្សនកិច្ចនៅភាគខាងត្បូងរដ្ឋកាលីហ្វូញ៉ា អំឡុងពេលដែលមាន ការបំផ្លិចបំផ្លាញដោយខ្យល់ សាន់តា អាណា បានកើតឡើងកាលពីចុងឆ្នាំមុន ។ ខ្ញុំបានចាកចេញពីទីនោះ ជាមួយនឹងចំណាប់អារម្មណ៍ពីរយ៉ាង ។ ចំណាប់អារម្មណ៍ទីមួយ គឺជារបៀបដែលសមាជិកសាសនាចក្របានមកជួយអ្នក ដែលស្ថិតនៅក្នុងសេចក្ដីត្រូវការ ។ ចំណាប់អារម្មណ៍ទីពីរ គឺជាអំណរគុណដែលពួកគេមានចំពោះក្រុមពន្លត់អគ្គីភ័យ ។ ម្ចាស់ផ្ទះម្នាក់បានរៀបរាប់នូវអ្វីដែលគាត់បានឃើញក្រុមពន្លត់អគ្គីភ័យធ្វើ ។ គាត់បានចង្អុលបង្ហាញថា ខ្យល់ សាន់តាអាណា បានបក់ពីតំបន់វាលខ្សាច់ឆ្ពោះទៅមហាសមុទ្រ ។ នៅគ្រាមួយអគ្គីភ័យបានឆាបឆេះ ខ្យល់មកពីវាលខ្សាច់ដ៏ក្ដៅទាំងនេះ បាននាំមកនូវអណ្ដាតភ្លើងដែលមានល្បឿនដល់ទៅ 60 ឬ 70 ម៉ៃល ( 97--113 គីឡូម៉ែត្រ) ក្នុងមួយម៉ោង ។ ម្ចាស់ផ្ទះរូបនោះបានរៀបរាប់នូវការដឹងគុណ និងការកោតសរសើររបស់គាត់ ពេលដែលគាត់បានឈរមើលក្រុមពន្លត់ អគ្គីភ័យដោយឈរជាមួយនឹងបំពង់ទឹករបស់ពួកគេខាងក្រោយតំបន់ដែលស្រឡះ ដោយបែរមុខទៅរកជញ្ជាំងកំពុងឆេះដែលមានកំពស់ 10 ហ្វីត (3 ម៉ែត្រ) ដោយធ្លាក់ចុះមកលើពួកគេនៅល្បឿនដ៏មហិមានេះ ។ ពួកបុរស និងស្ត្រីដ៏ឈ្លាសវៃទាំងនេះ បានជួយសង្គ្រោះទាំងមនុស្ស និងគេហដ្ឋាន ខណៈស្ថិតក្នុងគ្រោះថ្នាក់ផ្ទាល់ខ្លួនជាបន្តបន្ទាប់ ។

ម្ដងហើយម្ដងទៀត ក្នុងនាមជាបុគ្គលគ្រប់រូប និងជាសាសនាចក្រមួយ យើងឆ្លងកាត់នូវគ្រានៃវិបត្តិ និងគ្រោះថ្នាក់ ។ ហេតុការណ៍ខ្លះបានកើតឡើងយ៉ាងឆាប់រហ័សដូចជាភ្លើង ។ ហេតុការណ៍ផ្សេងៗទៀត មាននូវល្បិចកល ហើយកើតឡើងស្ទើរតែពុំបានដឹងជាមុន ពីមុនវាកើតមានឡើងចំពោះយើង ។ ខ្លះតំរូវឱ្យមាននូវសកម្មភាពក្លាហាន ប៉ុន្តែភាគច្រើនពុំមែនជាអ្វីដែលអស្ចារ្យនោះទេ ។ របៀបដែលយើងឆ្លើយតប គឺសំខាន់ណាស់ ។ គោលបំណងរបស់ខ្ញុំនៅរាត្រីនេះ គឺដើម្បីបញ្ជាក់ឡើងវិញទៅកាន់ពួកអ្នកកាន់បព្វជិតភាព នូវសារៈសំខាន់នៃការស្ដាប់តាមគ្រប់ទាំងពាក្យរបស់ពួកព្យាការី ។ នេះគឺជារបៀបដ៏ពិតប្រាកដមួយ ដើម្បីឆ្លើយតបទៅនឹងគ្រោះថ្នាក់ខាងលោកិយ និងខាងវិញ្ញាណគ្រប់ប្រភេទ ។ គំរូខ្លះប្រហែលជាមានប្រយោជន៍ ។

ពួកអ្នកទាំងអស់គ្នាភាគច្រើនបានចូលរួមនៅក្នុងការដើរដោយថ្មើរជើងដើម្បីទទួលនូវបទពិសោធន៍ និងថ្លែងអំណរគុណចំពោះការជួយសង្គ្រោះដ៏អស្ចារ្យរបស់ក្រុមរទេះរុញ វីលលី និងម៉ាទីន។ ដំបូងឡើយខ្ញុំបានដឹងអំពីការសង្គ្រោះនេះ កាលពីខ្ញុំនៅវ័យជំទង់។ ម្ដាយរបស់ខ្ញុំបានឱ្យសៀវភៅមួយក្បាលមកខ្ញុំ ដែលបានសរសេរដោយលោក អូសុន អែហ្វ វីឌនី ដែលក្រោយមកគាត់បានក្លាយជា សាវកមួយរូប។[2] សៀវភៅរបស់អែលឌើរ វីឌនី បានធ្វើឱ្យខ្ញុំស្គាល់នូវការខិតខំនៃបព្វបុរសដែលបានដឹកនាំដោយលោកព្រិកហាំ យ៉ង់ ដើម្បីសង្គ្រោះក្រុមរទេះរុញទាំងឡាយ។ ពួកលោកត្រូវបានជួបប្រទះនូវព្យុះនារដូវរងារ នៅកណ្ដាលទីវាលនៃទីក្រុង វ៉ាយអូមីង។ មានអ្នកខ្លះបានទទួលមរណភាព ហើយមនុស្សជាច្រើនទៀតស្ទើរតែស្លាប់។ លោកព្រិកហាំ យ៉ង់ បានដឹងជាមុននូវស្ថានភាពរបស់ពួកគេ ហើយនៅសន្និសីទទូទៅខែ តុលា ឆ្នាំ 1856 លោកបានណែនាំដល់ពួកបរិសុទ្ធឱ្យបញ្ឈប់រាល់សកម្មភាពផ្សេងៗ ហើយទៅសង្គ្រោះដល់ជនទាំងឡាយណាបានជាប់នៅទីវាលនោះ។[3]

ការឆ្លើយតប គឺអស្ចារ្យណាស់។ អែលឌើរ វីឌនី បានរាយការណ៍ថា: "ពួកបុរសដ៏ក្លាហានតាមរយៈវីរសម្បត្តិរបស់ពួកគេ--- ត្បិតវាគឺជាការគ្រោះថ្នាក់ដល់ជីវិត ផ្ទាល់ខ្លួនរបស់ពួកគេ ដែលថាពួកគេពិតជាក្លាហានដោយប្រឈមមុខនឹងព្យុះត្រជាក់នៅទីវាលនោះ--- ធ្វើឱ្យខ្លួនពួកគេអមតៈ ហើយឈ្នះលើបុគ្គលិកលក្ខណៈមិនខ្លាចស្លាប់នៃមនុស្សរាប់រយនាក់ ដែលត្រូវបានជួយសង្គ្រោះដោយគ្មានការសង្ស័យ ដោយសកម្មភាពគ្មានព្រំដែនរបស់ពួកគេពីការវិនាស"។[4]

មូលហេតុមួយដែលម្ដាយរបស់ខ្ញុំបានផ្ដល់ឱ្យសៀវភៅនោះមកខ្ញុំ គឺដោយសារអែលឌើរ វីឌនី បានធ្វើការលើកឡើងដ៏ពិសេសស្ដីពីលោកតាទួតរបស់ខ្ញុំ លោកតា ដាវីឌ ផាធើន ឃីមបឺល ដែលបានចូលរួមនៅក្នុងការសង្គ្រោះនៅពេលដែលលោកមានអាយុ 17 ឆ្នាំ។ ពួកអ្នកជួយសង្គ្រោះទាំងអស់បានប្រយុទ្ធនឹងព្រិលដ៏ជ្រៅ ហើយសីតុណ្ហភាពអំឡុងពេលមានជំនួយជាច្រើនមកពីក្រុមរទេះរុញ ។ ដោយសារការពលិកម្មផ្ទាល់ខ្លួនដ៏មហិមាលោកតា ដាវីឌ និងសហការីរបស់លោកបានជួយដល់ពួកអ្នកត្រួសត្រាយ ផ្លូវជាច្រើន ឆ្លងកាត់វាលទឹកកកនៅទន្លេស្វីតវ៉តធើរ។[5] ដំណើររឿងដ៏ពិតនេះបានធ្វើឱ្យខ្ញុំកោតសរសើរយ៉ាងជ្រាលជ្រៅ។ ខ្ញុំចង់បង្ហាញការពលិកម្មរបស់ខ្ញុំចំពោះព្រះអម្ចាស់ តាមរយៈសកម្មភាពដ៏អស្ចារ្យ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការទៅសួរសុខទុក្ខជាមួយនឹងលោកតា លោកបានពន្យល់ថា នៅពេលប្រធានព្រិកហាំ យ៉ង់ បានបញ្ជូនឪពុកលោកដាវីឌ និងយុវជនផ្សេងទៀតចំពោះបេសកកម្មសង្គ្រោះរបស់ពួកគេ ប្រធាន យ៉ង់ បានណែនាំពួកគេឱ្យធ្វើអ្វីៗគ្រប់យ៉ាង ដែលពួកគេអាចធ្វើបាន ដើម្បីបំរើក្រុមរទេះរុញ ទោះបីជាមានគ្រោះថ្នាក់ដល់ជីវិតរបស់ពួកគេផ្ទាល់ក្ដី។[6] ទង្វើដ៏ក្លាហានរបស់ពួកគេត្រូវបានគូសបញ្ជាក់ឱ្យ "ធ្វើតាមព្យាយការីព្រិកហាំ យ៉ង់" ហើយដោយការធ្វើដូច្នេះបង្ហាញនូវសេចក្ដីជំនឿរបស់ពួកគេលើព្រះអម្ចាស់ យេស៊ូវគ្រីស្ទ។ លោកតារបស់ខ្ញុំបានប្រាប់ខ្ញុំថាការលះបង់ដ៏ស្មោះត្រង់ ហើយខ្ជាប់ខ្ជួនចំពោះពាក្យប្រឹក្សារបស់ព្យាការី គឺជាមេរៀនពិតប្រាកដ ដែលខ្ញុំគួរតែរៀនមកពីការបំរើរបស់លោកតាទួតរបស់ខ្ញុំ។ វីរសម្បត្តិរបស់លោកតាទួត ដាវីឌ និងពួកសហការីរបស់លោក ក្នុងការជួយសង្គ្រោះដល់ពួកអ្នកត្រួសត្រាយផ្លូវ វាក៏សំខាន់នៅសព្វថ្ងៃនេះផងដែរ ក្នុងការធ្វើតាមពាក្យប្រឹក្សារបស់ព្យាការីរបស់យើង។

រឿងដែលត្រូវបានប្រាប់ជាញឹកញាប់ចេញពីព្រះគម្ពីរសញ្ញាចាស់ បានបង្ហាញគោលការណ៍នេះ។ ណាម៉ាន់ជាមេទ័ពដែលលេចធ្លោនៅស៊ីរី បានរងការឈឺចាប់ដោយជម្ងឺឃ្លង់។ គាត់បានដឹងថាព្យាការីអេលីយ៉ានៅអ៊ីស្រាអែល

ប្រហែលជាអាចព្យាបាលគាត់បាន។ ព្យាការីអេលីយ៉ា ផ្ញើសារតាមរយៈអ្នកនាំសារថា ណាម៉ាន់ គួរតែលាងសំអាតខ្លួនរបស់គាត់នៅក្នុងទន្លេជ័រដាន់ប្រាំពីរដង។ ដើមឡើយ ណាម៉ាន់ បានខឹងសម្បាជាមួយនឹងពាក្យទូន្មាននេះ។ ទោះជាយ៉ាងណាក៏ដោយ ពួកអ្នកបំរើរបស់គាត់ បាននិយាយថា:"បើសិនជាហោរានោះបានប្រាប់ឱ្យលោកធ្វើការអ្វីយ៉ាងធំ នោះតើលោកមិនធ្វើតាមទេឬអី?" បន្ទាប់មក ណាម៉ាន់ បានធ្វើតាមពាក្យទូន្មានរបស់ព្យាការី អេលីយ៉ា ហើយគាត់ត្រូវបានជាសះស្បើយ។7

ដូចជា ណាម៉ាន់ អ្នកទាំងអស់គ្នាដែលជាពួកអ្នកកាន់បព្វជិតភាពវ័យក្មេងអាចស្វែងរកដើម្បី "ធ្វើនូវរឿងដ៏អស្ចារ្យខ្លះ១" ឬចូលរួមក្នុងអ្វីមួយដែលអស្ចារ្យ ដូចជាការជួយសង្គ្រោះក្រុមរទេះរុញ។ ប៉ុន្តែ អ្នកទាំងអស់គ្នាគប្បីសំរេចចិត្តយ៉ាងរឹងមាំ ដើម្បីធ្វើតាមពាក្យទូន្មានរបស់ព្យាការី។ គណៈប្រធានទីមួយ បានបញ្ជាក់ជាថ្មីនូវការតាំងចិត្តរបស់ខ្លួនចំពោះការកើនឡើងនូវភាពសក្តិសមរបស់យុវវ័យ ដែលត្រូវបានធ្វើអនុសាសន៍សំរាប់ការបំរើជាអ្នកផ្សព្វផ្សាយសាសនា។ ដោយរក្សាខ្លួនរបស់អ្នកទាំងអស់គ្នា ឱ្យផុតពីអំពើបាបនៃលោកិយ ហើយដោយមាននូវបទដ្ឋានខ្ពស់សំរាប់ការបំរើជាអ្នកផ្សព្វផ្សាយសាសនា គប្បីមានគោលដៅមួយ។ ការរៀបចំខ្លួនរបស់អ្នកទាំងអស់គ្នាដើម្បីទទួលនូវការហៅពីព្យាការី ដើម្បីប្រកាសដំណឹងល្អ ហើយសង្គ្រោះកូនចៅមួយចំនួនរបស់ព្រះវរបិតាសួគ៌ខាងវិញ្ញាណ នឹងមាននូវសារៈសំខាន់ព្រមទាំងជាវីរសម្បត្តិ។ អ្នកទាំងអស់គ្នាអាចបំពេញតាមសំណូមពរនេះ។

ទូទាំងប្រវត្តិសាស្ត្រ ព្រះវរបិតាជាទីស្រឡាញ់ ដែលគង់នៅស្ថានសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដែលជាអ្នកដឹកនាំនៃសាសនាចក្រនេះ បានប្រទានពរឱ្យយើងនូវព្យាការីដែលទូន្មាន និងព្រមានអំពីគ្រោះថ្នាក់នាពេលអនាគត។8 នៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា កណ្ឌទី 21 និយាយជាក់លាក់អំពីព្យាការីព្រះអម្ចាស់បានប្រកាសថា:

"អ្នកត្រូវស្តាប់គ្រប់អស់ទាំងពាក្យសំដី និងបញ្ញត្តិទាំងឡាយរបស់លោកដែលលោកនឹងឱ្យដល់អ្នក នៅពេលលោកបានទទួលពាក្យទាំងនោះ ដោយដើរក្នុងបរិសុទ្ធភាពទាំងអស់ នៅចំពោះយើង

ត្បិតពាក្យសំដីរបស់លោកនោះហើយ អ្នកនឹងបានទទួលហាក់ដូចជាបានមកពីព្រះឱស្ឋរបស់យើងផ្ទាល់ ដោយសេចក្តីអត់ធន់ និងសេចក្តីជំនឿគ្រប់យ៉ាង"។9

នៅព្រឹកនេះ យើងមាននូវឯកសិទ្ធិដ៏អស្ចារ្យនៅក្នុងការជួបជុំដ៏ឧឡារិកមួយ ដើម្បីគាំទ្រប្រធាន ថូម៉ាស អេស ម៉នសុន ជាព្យាការី អ្នកមើលឆុត អ្នកទទួលវិវរណៈរបស់យើង និងជាប្រធានសាសនាចក្រទី 16 នៅក្នុងការកាន់កាប់ត្រួតត្រានេះ។ នៅក្នុងសម័យប្រជុំបព្វជិតភាពនៃសន្និសីទនេះ យើងនឹងត្រូវបានប្រទានឱ្យដោយបានស្តាប់នូវសុន្ទរកថាលើកដំបូងរបស់លោក ក្នុងនាមជាប្រធាននៃសាសនាចក្រនៅក្នុងសន្និសីទទូទៅ។ យើងនឹងចង់គាំទ្រលោកដោយអស់ពីដួងចិត្ត និងសកម្មភាពរបស់យើង ពេលដែលយើងយកចិត្តទុកដាក់ដោយ ប្រុងប្រយ័ត្នចំពោះអ្វីដែលលោកបង្រៀន និងអ្វីដែលយើងបានទទួលអារម្មណ៍។

សេចក្តីស្រឡាញ់ និងការដឹងគុណរបស់ខ្ញុំចំពោះព្យាការីមុនរបស់យើង ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ត្រូវបានកប់យ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់ខ្ញុំ ហើយនឹងបន្សល់នៅជាមួយនឹងរូបខ្ញុំដ៏នៅអស់កល្បជានិច្ច។ ប៉ុន្តែ ដូចជាយើងមានកន្លែងនៅក្នុងដួងចិត្តរបស់យើងសំរាប់កូនចៅទាំងអស់ ដែលបានចូលមកក្នុងគ្រួសាររបស់យើង យើងមាននូវសេចក្តីស្រឡាញ់ និងការពលិកម្មដូចគ្នានេះចំពោះព្យាការីនិមួយៗ ដែលព្រះអម្ចាស់ហៅដើម្បីដឹកនាំសាសនាចក្ររបស់ទ្រង់។

ពួកព្យាការីត្រូវបានបំផុសគំនិតដើម្បីផ្តល់ឱ្យយើងនូវអាទិភាពដែលទាយទុកជាមុន ដើម្បីការពារយើងពីគ្រោះថ្នាក់ទាំងឡាយ។ ដូចជាឧទាហរណ៍មួយ ប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត ជាព្យាការីពីឆ្នាំ 1918 ដល់ 1945 ត្រូវបានបំផុសគំនិតឱ្យបញ្ជាក់នូវ ការប្រកាន់ខ្ជាប់ចំពោះ ពាក្យគតិបណ្ឌិត 10 ជាគោលការណ៍ដោយសេចក្តីសន្យា ដែលបានបើកសម្តែងដោយព្រះអម្ចាស់ ដល់ព្យាការីយ៉ូសែប។[11] លោកបានសង្កត់ធ្ងន់នូវសារៈសំខាន់នៃការមិនជក់ ឬផឹកគ្រឿងស្រវឹង ហើយបានណែនាំ ពួកប៊ីស្សពឱ្យរំឭកនូវគោលការណ៍ទាំងនេះឡើងវិញ នៅក្នុងការសម្ភាសន៍ចេញនូវអនុសាសន៍ចូលព្រះវិហារបរិសុទ្ធ។

នៅគ្រានោះ ការជក់ថ្នាំជក់ត្រូវបានទទួលយកដោយសង្គមថាជាការសមរម្យ ចំពោះភាពស្រស់បំព្រង និងចំពោះឥរិយាបទ។ ការអះអាងខាងវិជ្ជាពេទ្យបានទទួលយកថា ការជក់ថ្នាំជក់មាននូវបញ្ហាបន្តិចបន្តួច ពីព្រោះការសិក្សាខាងវិទ្យាសាស្ត្រ បានចង្អុលបង្ហាញការជក់បារីទៅនឹងប្រភេទនៃជម្ងឺមហារីកមួយចំនួននៅពេលក្រោយមក។ ប្រធានក្រាន្តបានទូន្មានជាមួយនឹងកម្លាំងដ៏មហិមា ហើយយើងត្រូវបានគេស្គាល់ថា ជាមនុស្សមួយក្រុម ដែលជៀសវាងពីការជក់បារី និងផឹកគ្រឿងស្រវឹង។

ជាការចាប់ផ្តើមនៅចុងឆ្នាំ 1960 ការប្រើប្រាស់ថ្នាំខុសច្បាប់បានរីកដុះដាលទូទាំងពិភពលោក។ ខណៈដែលមានសមាជិកខ្លះបានបះបោរ យុវវ័យ អិល. ឌី. អេស យ៉ាងច្រើន អាចជៀសវាងនូវគ្រោះថ្នាក់ នៃការប្រើប្រាស់ថ្នាំ។

ការគោរពតាមច្បាប់គតិបណ្ឌិតផ្តល់ឱ្យសមាជិករបស់យើង ជាពិសេសយុវវ័យរបស់យើង នូវការចាក់ថ្នាំបង្ការប្រឆាំងនឹងការប្រើប្រាស់ថ្នាំ និងមានលទ្ធផលចេញជាបញ្ហាសុខភាព ព្រមទាំងគ្រោះថ្នាក់ខាងសីលធម៌។ ជាអកុសលមានបង្ហាញឱ្យឃើញថាមានការលេចឡើងជាថ្មីនូវការប្រើប្រាស់ថ្នាំ នៅក្នុងសម័យយើងនេះផ្ទាល់។ ការរស់នៅតាមពាក្យគតិបណ្ឌិតនៅសម័យនេះ នឹងជួយអ្នកទាំងអស់គ្នាឱ្យរួចផុតពីគ្រោះថ្នាក់ដ៏ធំបំផុតមួយចំនួន ដែលអ្នកអាចជួបប្រទះនៅក្នុងជីវិតនេះ។

ពេលខ្លះ ពួកព្យាការីបង្រៀនយើងអាទិភាពដែលទាយទុកជាមុន ដែលផ្តល់នូវការការពារចំពោះយើងនាពេលបច្ចុប្បន្ន និងអនាគត។ ឧទាហរណ៍ ប្រធាន ដាវីឌ អូ មិកឃេ ជាព្យាការីពីឆ្នាំ 1951 ដល់ 1970។ ផ្នែកយកចិត្តទុកដាក់ដ៏សំខាន់មួយ គឺការគូសបញ្ជាក់របស់លោកលើគ្រួសារ។ លោកបានបង្រៀនថា គ្មានជោគជ័យណាមួយនៅក្នុងជីវិតដែលអាចប្រៀបស្មើនឹងការបរាជ័យនៅក្នុងគេហដ្ឋានឡើយ ។[12] លោកបានលើកទឹកចិត្តដល់សមាជិកឱ្យពង្រឹងក្រុមគ្រួសារ តាមរយៈការបង្កើននូវការអនុវត្តន៍ខាងសាសនា។ ការបង្រៀនរបស់លោក គឺជាការការពារមួយចេញពីការបំបែកចេញនៃស្ថាប័នអាពាហ៍ពិពាហ៍ ដែលបានបង្កើតឡើង បន្ទាប់ពីមរណភាពរបស់លោក។[13] ដោយសារការបង្រៀនរបស់ប្រធាន មិកឃេ ពួកបរិសុទ្ធថ្ងៃចុងក្រោយ បានពង្រឹងនូវការតាំងចិត្តរបស់ពួកគេចំពោះគ្រួសារ និងអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច។

ក្នុងនាមជាអ្នកកាន់បព្វជិតភាពនៃសាសនាចក្រនេះ វាគឺជាការទទួលខុសត្រូវដ៏ធំរបស់យើង ដើម្បីធ្វើតាមព្យាការីរបស់យើង។ យើងសូមគាំទ្រប្រធានម៉នសុន និងទីប្រឹក្សារបស់លោក ប្រធានអាវរិង និងប្រធាន អុជដូហ្វ។

យើងចង់ឱ្យអ្នកទាំងអស់គ្នាដែលជាយុវវ័យដឹងថា ប្រធានថូម៉ាស អេស ម៉នសុន ត្រូវបានរៀបចំដោយព្រះអម្ចាស់ ចាប់តាំងពីយុវវ័យរបស់លោកមកម្ល៉េះ ដើម្បីធ្វើជាព្យាការី។[14] បន្ទាប់ពី ការបំរើនៅក្នុងកងនាវានៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរមក លោកត្រូវបានតែងតាំងជាប៊ីស្សពក្នុងវ័យ 22 ឆ្នាំ ហើយក្រោយមក

បានបំរើជាគណៈប្រធាននៃស្តេក។ ក្នុងវ័យ 32 ឆ្នាំ លោកបានបំរើជា ប្រធានបេសកកម្មនៅក្នុងប្រទេសកាណាដា ជាមួយនឹងភរិយាសំណប់ និងជាដៃគូរបស់លោក គឺលោកស្រីហ្វ្រែនស៊ីស ម៉ូនសុន។ លោកត្រូវបានហៅឱ្យធ្វើជាសាវក ដោយប្រធានមិកឃេ ពេលដែលលោកមានវ័យ 36 ឆ្នាំប៉ុណ្ណោះ។ លោកគឺជាបុរសដែលមានវ័យក្មេងជាងគេបង្អស់ ដែលបានហៅឱ្យធ្វើជាសាវកនៅក្នុងរយៈពេល 98 ឆ្នាំនេះ និងត្រូវបានបំរើអស់រយៈពេល 44 ឆ្នាំ។ រយៈពេល 22 ឆ្នាំចុងក្រោយនេះ លោកបានបំរើជាទីប្រឹក្សារបស់ប្រធាន អែសរ៉ា ថាហ្វ បែនសឹន ប្រធាន ហាវើដ ដបុលយូ ហ៊ីនធើរ និង ប្រធាន ហ្គរដុន ប៊ី ហ៊ីងគ្លី ។15

កណ្ឌទី 81 នៃគោលលទ្ធិ និង សេចក្តីសញ្ញាផ្តល់នូវការណែនាំទៅដល់ទីប្រឹក្សាមួយរូបនៅក្នុងគណៈប្រធានទីមួយ។ វាមាននូវគោលការណ៍សំខាន់នៃបព្វជិតភាព។ ការណែនាំដំបូង គឺមាន "ចិត្តស្មោះត្រង់នៅក្នុងការទូន្មាន"។ ប្រធានម៉ូនសុន បានប្រឹក្សាយ៉ាងស្មោះត្រង់ជាមួយនឹងព្យាការីទាំងបីរូប ដែលលោកបានបំរើ។ សាមគ្គីភាពរបស់គណៈប្រធានទីមួយ នៅរាល់ការសំរេចចិត្តសំខាន់ៗ បានធ្វើជាគំរូដល់យើងទាំងអស់គ្នា ដែលជាអ្នកកាន់បព្វជិតភាពនៅក្នុងកិច្ចការនៃការគ្រប់គ្រងសាសនាចក្រ។

ការណែនាំទីពីរ គឺ "ការប្រកាសដំណឹងល្អ" ។ ប្រធាន ម៉ូនសុន ជាអ្នកផ្សព្វផ្សាយសាសនាដ៏ឆ្នើមមួយរូបពេញមួយជីវិតរបស់លោក។ ការប្រឹងប្រែងខាងការផ្សព្វផ្សាយសាសនាផ្ទាល់របស់លោក ការងារគ្រប់គ្រងនៃផ្នែកអ្នកផ្សព្វផ្សាយសាសនារបស់លោក និងការហៅ ព្រមទាំងការបំពាក់បំប៉នដល់ប្រធានបេសកកម្មទាំងឡាយរបស់លោក ត្រូវបានគេទទួលយកជាមួយនឹងការស្ញើចសរសើរ។ លោកបានធ្វើនូវការបរិច្ចាគដ៏សំខាន់ចំពោះសៀវណែនាំថ្មីសំរាប់អ្នកផ្សព្វផ្សាយសាសនា *ប្រកាសដំណឹងល្អរបស់យើង* ។ បន្ថែមពីលើ បញ្ជីបរិច្ចាគដ៏មានតម្លៃ លោកបានបំផុសគំនិតនូវការបញ្ចប់នូវនូវរឿងពិតទាំងឡាយ ដើម្បីធ្វើជាការណែនាំឱ្យរស់រវើក។ ជាមួយនឹងបទពិសោធន៍ដែល លោកមានជាអ្នកបោះពុម្ព លោកបានធ្វើឱ្យការរចនា និងរូបរាងខាងក្រៅកាន់តែមានភាពប្រសើរឡើង។ ពិតណាស់ លោកគឺជាអ្នកផ្សព្វផ្សាយសាសនាដ៏ឆ្នើម។

ការណែនាំទីបី អានថា "ហេតុដូច្នោះហើយ ចូរមានចិត្តស្មោះត្រង់ចុះ ចូរឈរនៅក្នុងតំណែងដែលយើងបានតែងតាំងដល់អ្នក ចូរជួយអ្នកទន់ខ្សោយ ចូរលើកដៃដែលរោយ ហើយចូរចំរើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រផង។16 បងប្អូនប្រុសស្រីរបស់យើងជាច្រើន ប្រឈមមុខនឹងបញ្ហាទុក្ខសោកនៅក្នុងជីវិតរបស់ពួកគេ។ វាគឺស្ថិតនៅក្នុងការឈោងទៅជួយដែលមានលក្ខណៈដូចជាព្រះគ្រីស្ទរបស់យើងចំពោះពួកគេ ដែលយើងក្នុងនាមជាអ្នកដឹកនាំបព្វជិតភាព ឪពុកម្តាយ មិត្ត និងគ្រូបង្រៀនតាមផ្ទះ អាចធ្វើដូចជាអ្នកជួយសង្គ្រោះដល់ក្រុមរទេះរុញ។

កិច្ចប្រឹងប្រែងនៃការសង្គ្រោះរបស់ប្រធានម៉ូនសុន ដែលគួរឱ្យកោតសរសើរនេះ បានក្លាយជាគំរូយ៉ាងសំខាន់។ ក្នុងមានជាប៊ីស្សពមួយរូប លោកបានរៀនបំរើដល់សមាជិកវួដរបស់លោក។ លោកបានរក្សានូវទំនាក់ទំនង ហើយបានបំរើកូន ព្រមទាំងចៅរបស់ពួកគេ។ ទោះបីជាកាលវិភាគមមាញឹក តែលោកអាចនិយាយនៅឯពិធីបុណ្យសពនៃស្ត្រីមេម៉ាយដែលរស់នៅក្នុងវួដរបស់លោក សរុបទាំងអស់ចំនួន 84 អ្នកដែលនៅក្នុងវួដរបស់លោក ពេលដែលលោកធ្វើជាប៊ីស្សព។

លោកបានឈោងទៅជួយដល់ជនទាំងឡាយណា ដែលកំពុងត្រូវការជំនួយ ដោយមធ្យោបាយផ្ទាល់ខ្លួន ហើយអស្ចារ្យបំផុត។ កិច្ចខិតខំខាងសប្បុរសធម៌ជាច្រើន ឆ្នាំរបស់លោក បានប្រទានពរដល់មនុស្សជុំវិញពិភពលោក ទាំងសមាជិក និងជនទាំងឡាយដែនមិនជាសមាជិក។ ការបំរើផ្ទាល់ខ្លួនរបស់លោក មានលក្ខណៈដូចជាព្រះគ្រីស្ទ ហើយបានផ្ដល់នូវការលួងលោម និងសេចក្ដីសុខសាន្តដល់មនុស្សជាច្រើនរាប់មិនអស់។ មិត្តរបស់ខ្ញុំម្នាក់ដែលបានបាត់បង់ចៅប្រុសនៅក្នុងសោកនាដកម្មមួយ បានប្រាប់ខ្ញុំថា ការសោកសៅរបស់គាត់ គឺស្ទើតែពុំអាចថ្លែងបាន។ ការបំរើរបស់ប្រធាន ម៉នសុន ចំពោះគាត់ បានបង្វែរភាពសោកសៅ ទាំងនោះមកជាសេចក្ដីសុខសាន្តដែលហួសលើសពីអស់ទាំងការយល់ដឹង។ កិច្ចប្រឹងប្រែងរបស់លោក ដែលបំរើដោយផ្ទាល់ដល់ជនទាំងឡាយ ដែលមានជម្ងឺ ហើយបានរងទុក្ខ គឺអស្ចារ្យណាស់។

ប្រធានម៉នសុន បានធ្វើកិច្ចការអស់ពីសមត្ថភាពរបស់លោក ដើម្បី "ជួយអ្នកទន់ខ្សោយ ចូរលើកដៃដែលរោយ ហើយចូរចំរើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រផង"។17 លោកបានស្អាងការហៅរបស់លោកជាទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយ តាមមធ្យោបាយដ៏អស្ចារ្យ។ លោកបានថ្លែងទីបន្ទាល់យ៉ាងក្លាហានអំពីព្រះ នាមនៃព្រះគ្រីស្ទនៅពាសពេញពិភពលោក ដែលជាការទទួលខុសត្រូវចម្បងនៃពួកសាវកទាំងអស់។

ក្នុងនាមជាសមាជិកក្មេងខ្ចីនៃពួក 12 នាក់ ការចូលរួមនៅក្នុងការរៀបចំដំបូង នៃគណៈប្រធានទីមួយនៅបន្ទប់ខាងលើនៃព្រះវិហារបរិសុទ្ធ សលត៏ លេក កាលពីខែ កុម្ភៈកន្លងទៅនេះ ខ្ញុំបានមានបទពិសោធន៏នូវការបញ្ជាក់ពីព្រះវិញ្ញាណ ក្នុងនាមជាពួក 12 នាក់ដោយផ្ទាល់ខ្លួន និងបានគាំទ្រជាឯកច្ឆ័ន្ទដល់ប្រធាន ម៉នសុន ជាព្យាការីរបស់ព្រះ និងជាប្រធាន នៃសាសនាចក្រ។

ខ្ញុំមានអំណរគុណសំរាប់ព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ ដែលទ្រង់ស្រឡាញ់យើង និងព្រះរាជបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ។ ទ្រង់គឺជាព្រះអង្គសង្គ្រោះរបស់យើង ហើយតាមរយៈដង្វាយធួនរបស់ទ្រង់ដែលជាអង្គសង្គ្រោះដ៏ពិតរបស់យើងពីគ្រោះថ្នាក់ខាងរូបកាយ និងខាងវិញ្ញាណនៃជីវិត។ ទ្រង់គឺជាអង្គគាំទ្ររបស់យើងជាមួយព្រះវរបិតា។ អ្វីៗទាំងអស់នេះខ្ញុំសូមធ្វើជាសាក្សីនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. សូមមើលយ៉ូហាន 15:13។

2. សូមមើល Orson F. Whitney, *Life of Heber C. Kimball* បោះពុម្ពលើកទី 2 1945 ទំព័រ 413--14។

3. សូមមើល Gordon B. Hinckley, "The Faith to Move Mountains," *Liahona* ខែវិច្ឆិកា ឆ្នាំ 2006, 83--84។

|4. *Life of Heber C. Kimball,* 413។

5. សូមមើល Chad M. Orton, "The Martin Handcart Company at the Sweetwater: Another Look," *BYU Studies,* វ៉ុលទី 45 លេខ 3, (2006) ទំព័រ 5--37។

6. សូមមើល Marva Jeanne Kimball, Pedersen *Crozier Kimball, His Life and Work*, (Salt Lake City: Crozier Kimball Family, 1995), 6--7។

7. សូមមើលពង្សាវតារក្សត្រទី 2 5:1--14។

8. សូមមើលអេម៉ុស 3:7 ។

9. គ. និង ស. 21:4--5 ។

10. Grant, Heber J. ˝ការសង្កេតមើលពីពាក្យគតិបណ្ឌិត˝ *Teachings of Presidents of the Church: Heber J. Grant* (Melchizedek Priesthood and Relief Society course of study, 2002) 189--197 ។

11. សូមមើល គ. និង ស. 89 ។

12. បានដកស្រង់ចេញពី J.E. McCulloch, *Home: The Savior of Civilization* (1924), 42 នៅក្នុង Conference Report ខែ មេសា ឆ្នាំ1935, 116 ។

13. សូមមើល Brad Schiller " The Inequality Myth," *Wall Street Journal* ថ្ងៃទី 10 ខែ មីនា ឆ្នាំ 2008 A15 ។

14. សូមមើលឧទាហរណ៍ខាងក្រោម: សាំយ៉ូអែលទី1 2:26 មរមន 1:2 យ៉ូសែប ស្ម៊ីធ---ប្រវត្តិ 1:7 ។

15. See *Deseret Morning News* 2008 Church Almanac, (2007), 35 ។

16. គ. និង ស. 81:3--5 ។